# ប្រទេសកម្ពុជា

| | ឆ្នាំ ២០១៤ |
|---|---|
| ប្រជាជនសរុប គិតជាលាននាក់ | 15.1 |
| GDP គិតជាពាន់លានដុល្លាអាមេរិក | 16.1 |
| GDP សម្រាប់មនុស្សម្នាក់គិតជាដុល្លាអាមេរិក (ឆ្នាំ២០១៣) | 1,006.8 |
| GDP សម្រាប់មនុស្សម្នាក់ គិតជាដុល្លាអាមេរិក(PPP) (ឆ្នាំ ២០១៣) | 3,041.1 |
| សន្ទស្សន៍ Gini (ការប៉ាន់ប្រមាណរបស់ធនាគារពិភពលោក) (ឆ្នាំ២០១២) | 28.8 |
| អត្រាភាពក្រីក្រជាតិ (ឆ្នាំ២០១២) 1/ | 17.7 |
| អត្រាភាពក្រីក្រ ១,២៥ ដុល្លាអាមេរិកក្នុងមួយថ្ងៃ (PPP) (ឆ្នាំ ២០១២) (%) 2/ | 6.0 |
| អាយុសង្ឃឹមរស់ពេលកើត សរុប (ឆ្នាំ) (ឆ្នាំ២០១២) | 71 |
| អត្រាចុះឈ្មោះចូលរៀនថ្មី កម្រិតបឋមសិក្សា (សរុបគិតជា %) (ឆ្នាំ២០១២) | 98 |

ប្រភព ៖ សូចនាករអភិវឌ្ឍន៍សកល និងការប៉ាន់ប្រមាណរបស់បុគ្គលិកធនាគារពិភពលោក
1/ បន្ទាត់ភាពក្រីក្រជាតិឆ្នាំ២០១២ ៖ ៥.៣២៦ រៀល សម្រាប់ភ្នំពេញ ៤.២៧៣ រៀល សម្រាប់តំបន់ទីក្រុងផ្សេងទៀត និង ៣.៩១៤ រៀលសម្រាប់គ្រួសាររស់នៅជនបទ។
2/ ១,២៥ ដុល្លាអាមេរិកក្នុងមួយថ្ងៃ(PPP)ក្នុងឆ្នាំ២០១២ ប្រហាក់ប្រហែលនឹង ៣.៦០៥ រៀល (តម្លៃជាក់ស្តែង)។

***ប្រទេសកម្ពុជានៅតែបន្តមានកំណើនសេដ្ឋកិច្ចដ៏រឹងមាំ ទោះបីជាមានល្បឿនកំណើនយឺតបន្តិចក៏ដោយ។*** *កំណើនពិតសម្រាប់ឆ្នាំ ២០១៤ ត្រូវបានប៉ាន់ស្មានថានឹងកើនដល់ ៧,០ ភាគរយ (រូបលេខ ១) ប៉ុន្តែមានសញ្ញាណបង្ហាញពីចំណុចខ្សោយក្នុងផលិតកម្មសម្លៀកបំពាក់ និងកសិកម្មដែលកំពុងធ្វើឲ្យល្បឿនកំណើនយឺតបន្តិច។*

***ភាពក្រីក្រនៅតែបន្តថយចុះក្នុងប្រទេសកម្ពុជា។*** *នៅឆ្នាំ ២០១២ អត្រានៃភាពក្រីក្រ (យោងតាមបន្ទាត់ក្រីក្រជាតិ) មានចំនួន ១៧,៧ ភាគរយ ដែលទាបជាងជិត ៣ ភាគរយនៃអត្រាភាពក្រីក្រក្នុងឆ្នាំ២០១១។ លើសពីនេះទៀត កំណើនសេដ្ឋកិច្ចនាពេលថ្មីៗនេះ មានភាពល្អប្រសើរចំពោះអ្នកដែលមិនមានជីវភាពធូរធារ។*

## *វឌ្ឍនភាពថ្មីៗ*

**ការនាំចេញសម្លៀកបំពាក់**មានកំណើនត្រឹម ៩,២ ភាគរយ (គិតជាតម្លៃ) ក្នុងឆ្នាំ២០១៤ បើធៀបនឹងឆ្នាំ២០១៣ អត្រាកំណើននេះ ១៧,៦ ភាគរយ។ ល្បឿនកំណើនទាបជាងនេះបណ្តាលមកពីការរំដើបរំជួលរបស់កម្មករកាលពីពេលមុន កំណើនតម្លៃប្រាក់ដុល្លា និងការលេចឡើងនូវប្រទេសប្រកួតប្រជែងផ្សេងទៀតក្នុងតំបន់ដែលផ្តល់ប្រាក់ឈ្នួលទាប។

**វិស័យសំណង់នៅតែមានភាពរឹងមាំ** ដោយសារតែការទទួលបានទំនុកចិត្តឡើងវិញ។

**អត្រាកំណើននៃភ្ញៀវទេសចរ ឆ្នាំ២០១៤ មានការថយចុះ** ដោយមានត្រឹមតែ ៦,៩ ភាគរយ បើធៀបនឹងឆ្នាំ ២០១៣ អត្រានេះមានចំនួន ១៧,៥ ភាគរយ ដោយសារតែការធ្លាក់ចុះនៃវិស័យទេសចរណ៍ក្នុងតំបន់។

**កំណើនវិស័យកសិកម្មមានភាពយឺតយ៉ាវ** ដោយសារតែកំណើនទិន្នផលយឺត បូករួមនឹងការធ្លាក់ចុះនៃតម្លៃផលិតផលកសិកម្ម។

**វិស័យទូទាត់ក្រៅប្រទេសនៅតែមានស្ថិរភាព ដោយសារតែលំហូរវិនិយោគផ្ទាល់ពីបរទេសដ៏ប្រសើរ។** ដោយសារតែការនាំចេញមានការថយចុះ ឱនភាពគណនីចរន្ត (មិនគិតការបង្វែរផ្លូវការ) បានកើនឡើងបន្តិចទៅដល់ តាមការប៉ាន់ស្មាន ១១,២ ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០១៤។ ទុនបម្រុងអន្តរជាតិដុល មានការកើនឡើងរហូតដល់ ៤,៦ ពាន់លានដុល្លាអាមេរិក ឬប្រហែល ៤,០ ខែនៃការនាំចូល គិតត្រឹមបំណាច់ឆ្នាំ២០១៤។

**ការកំណត់អត្រាប្តូរប្រាក់ជួយដល់ស្ថិរភាពតម្លៃ ប៉ុន្តែធ្វើឲ្យប៉ះពាល់ដល់ការប្រកួតប្រជែងនៃការនាំចេញទៅកាន់ទីផ្សារអឺរ៉ុប។** ប្រាក់រៀលមានតម្លៃប្រហែល ៤.០០០ រៀល ក្នុង ១ ដុល្លាអាមេរិក ប៉ុន្តែបានកើនតម្លៃបើធៀបនឹងប្រាក់អឺរ៉ូប្រមាណ ១៧ ភាគរយ តាំងពីខែកក្កដា ឆ្នាំ២០១៤ មក។

**អតិផរណាបានធ្លាក់ចុះយ៉ាងខ្លាំងមកត្រឹម ១,២ ភាគរយ** នៅចុងឆ្នាំ ២០១៤ បើធៀបនឹងចុងឆ្នាំ២០១៣ អត្រាអតិផរណាមានប្រមាណ ៤,៦ ភាគរយ ដោយសារតែការធ្លាក់ចុះតម្លៃគ្រឿងឧបភោគបរិភោគ និងប្រេង។

**ភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុនៅតែបន្តមាន។** អត្រាកំណើនប្រាក់បញ្ញើរបស់វិស័យឯកជនបានកើនឡើងលើសពីទ្វេរដងរហូតដល់ ៣០,៦ ភាគរយត្រឹមចុងឆ្នាំ ២០១៤ បើធៀបនឹងចុងឆ្នាំ ២០១៣ អត្រាកំណើននេះមានតែ ១៤,២ ភាគរយ

ប៉ុណ្ណោះ។ អត្រាកំណើនឥណទានក៏មានការកើនឡើងសារជាថ្មីដែរ ដោយកើនរហូតដល់ ៣១,៣ ភាគរយនៅចុងឆ្នាំ ២០១៤។

**ការពង្រឹងផ្នែកសារពើពន្ធនៅតែបន្ត។** ការប្រមូលចំណូលបានកើនរហូតដល់ តាមការប៉ាន់ស្មាន ១៦,១ ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៤ បើធៀបនឹងឆ្នាំ ២០១៣ ការប្រមូលចំណូលមានចំនួន ១៥,១ ភាគរយនៃផលិតផលក្នុងស្រុកសរុប។ ការចំណាយនៅតែដដែលត្រឹម ២០,៥ ភាគរយនៃផលិតផលក្នុងស្រុកសរុប។ យ៉ាងណាក៏ដោយ ឱនភាពសារពើពន្ធសរុប (រួមទាំង ជំនួយឥតសំណង) មានការថយចុះតិចតួចប៉ុណ្ណោះ ត្រឹម ២,៥ ភាគរយនៃផលិតផលក្នុងស្រុកសរុបនេះ ក៏ដោយសារតែការថយចុះនៃជំនួយឥតសំណង។ តាមការវាយតម្លៃដោយការវិភាគរួមគ្នារវាងធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិអំពីនិរន្តរភាពបំណុល (ឆ្នាំ២០១៣) ចំណាត់ថ្នាក់ភាពតានតឹងផ្នែកបំណុលរបស់ប្រទេសកម្ពុជានៅមានកម្រិតទាបនៅឡើយទេ។

**ជារួម កំណើនសេដ្ឋកិច្ចបានជួយដល់ប្រជាជនក្រីក្រ។** ដោយសារតែភាពសកម្មនៃវិស័យកសិកម្ម ការប្រើប្រាស់របស់អ្នកដែលស្ថិតនៅកម្រិត ៤០ ភាគរយខាងក្រោមនៃរបាយនៃការប្រើប្រាស់ បានកើនឡើងដោយមានអត្រាកំណើនជាមធ្យមប្រចាំឆ្នាំ ៧ ភាគរយ ក្នុងអំឡុងឆ្នាំ ២០០៧-២០១២ នៅខណៈដែលអត្រាកំណើនសរុបមានតែ ៣,៦ ភាគរយប៉ុណ្ណោះ។ ស្របពេលជាមួយគ្នានេះដែរ វិសមភាពមានភាពប្រសើរឡើងវិញ។ មេគុណ Gini បានថយចុះពី ៣២ ក្នុងឆ្នាំ ២០០៨ មកត្រឹម ២៨ ក្នុងឆ្នាំ២០១២។ យ៉ាងណាក៏ដោយ អត្រាកំណើនសមភាពបានថយចុះក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

**នៅចន្លោះឆ្នាំ ២០០៤ និង ២០១២ អត្រាភាពក្រីក្របានធ្លាក់ចុះយ៉ាងខ្លាំង ពី ៥០,២ ភាគរយ មកត្រឹម ១៧,៧ ភាគរយផ្អែកតាមបន្ទាត់ភាពក្រីក្រជាតិ។** ការកាត់បន្ថយភាពក្រីក្រភាគច្រើនកើតមាននៅចន្លោះឆ្នាំ ២០០៧ និងឆ្នាំ ២០០៩ (ជាង ២០ ភាគរយ) ដែលភាគច្រើនកើតឡើងដោយសារតែការកើនឡើងយ៉ាងខ្ពស់នៃតម្លៃស្រូវ ដែលជាផលិតផលកសិកម្មដ៏សំខាន់របស់ប្រទេសកម្ពុជា។ ភាពក្រីក្រនៅតាមតំបន់ជនបទនៅតែមានប្រេវ៉ាឡង់ខ្ពស់ជាងភាពក្រីក្រនៅទីក្រុង ក្នុងឆ្នាំ ២០១២។ អត្រាភាពក្រីក្រនៅតំបន់ជនបទមានចំនួន ២១,០ ភាគរយ បើធៀបនឹងទីក្រុង អត្រានេះមានចំនួន ៨,៦ ភាគរយ (នៅទីក្រុងភ្នំពេញមានប្រជាជនក្រីក្រប្រមាណតែ ៣,៨ ភាគរយប៉ុណ្ណោះ)។

### *ស្ថានភាពនាពេលអនាគត*

**តាមការព្យាករណ៍ កំណើនសេដ្ឋកិច្ចនឹងថយចុះបន្តិចមកត្រឹម ៦,៩ ភាគរយក្នុងឆ្នាំ២០១៥។** ការថយចុះនៃការប្រកួតប្រជែងដោយសារការកើនឡើងនៃការចំណាយ ការកើនតម្លៃប្រាក់ដុល្លា និងប្រទេសប្រកួតប្រជែងថ្មី នឹងបន្តប៉ះពាល់ដល់កំណើននាំចេញសម្លៀកបំពាក់ ខណៈដែលការសម្រេចបានអត្រាកំណើនពីរខ្ទង់ នៃការចូលទស្សនារបស់ភ្ញៀវទេសចរជាថ្មីម្តងទៀត មិនទាន់មានភាពប្រាកដប្រជានៅឡើយ។ កំណើនវិស័យកសិកម្មនឹងនៅតែមានកម្រិតទាបដដែល ដោយសារការថយចុះតម្លៃផលិត ផលកសិកម្ម និងកំណើនទិន្នផលដំណាំយឺត។

**ផលប៉ះពាល់ដែលរំពឹងទុកថាមានភាពវិជ្ជមាននៃការធ្លាក់ចុះតម្លៃប្រេងនាពេលថ្មីៗនេះ មានកម្រិតខ្ពស់ទៅលើកំណើន (០,៥ ភាគរយនៃកំណើនផលិតផលក្នុងស្រុកសរុបសម្រាប់ឆ្នាំនេះ) ប៉ុន្តែផលប៉ះពាល់នេះមានកម្រិតទាបណាស់ចំពោះភាពក្រីក្រ។** ការធ្លាក់ចុះតម្លៃប្រេងក្នុងស្រុកចំនួន ២០ ភាគរយ យ៉ាងច្រើនបំផុតធ្វើឲ្យមានកំណើននៃការប្រើប្រាស់ចំនួន ១,៥ ភាគរយសម្រាប់គ្រួសារដែលមានប្រាក់ចំណូលមធ្យម ហើយកំណើននៃការប្រើប្រាស់នេះមានកម្រិតទាបជាងសម្រាប់គ្រួសារក្រីក្រ ដោយសារតែការចំណាយទៅលើប្រេងរបស់ពួកគេមានចំនួនតិចជាង។

រូបលេខ ១ ៖ ប្រទេសកម្ពុជា ការរួមចំណែកដល់កំណើនផសសពិត
(គិតជាភាគរយ)




ប្រភព ៖ អាជ្ញាធរ និង ការប៉ាន់ស្មាន និងការព្យាករណ៍របស់បុគ្គលិកធនាគារពិភពលោក
e= ការប៉ាន់ស្មាន p= ការព្យាករណ៍

រូបលេខ ២ ៖ ប្រទេសកម្ពុជា កំណើនផសសសម្រាប់មនុស្សម្នាក់ៗ
និងអត្រាភាពក្រីក្រ




ប្រភព ៖ អាជ្ញាធរ និង ការប៉ាន់ស្មាន និងការព្យាករណ៍របស់បុគ្គលិកធនាគារពិភពលោកប្រើប្រាស់ ទិន្នន័យ CSES

**ហានិភ័យមួយចំនួន** រួមមាន ការរំជើបរំជួលរបស់កម្មករដែលអាចកើតឡើងជាថ្មី ភាពយឺតយ៉ាវនៃការស្តារសេដ្ឋកិច្ចឡើងវិញនៅអឺរ៉ុប និងការបន្តថយចុះតម្លៃអង្ករដោយសារតែការចូលក្តុបទីផ្សារឡើងវិញរបស់រដ្ឋាភិបាលថៃនិងមីយ៉ាន់ម៉ា។

## *បញ្ហាប្រឈម*

**ការស្តារឡើងវិញ ចំពោះកត្តាជំរុញឲ្យមានកំណើនដែលជា វិស័យកាត់ដេរ ទេសចរណ៍ និងអង្ករ គឺជាបញ្ហាសំខាន់ជាគន្លឹះ។** ការដោះស្រាយបញ្ហាចំណាយខ្ពស់លើ អគ្គិសនី ស្វ័យប្រវត្តិកម្មដំណើរការធុរកិច្ច និងការពង្រឹងបរិយាកាសវិនិយោគ នឹងបង្កើនការប្រកួតប្រជែង និងការធ្វើពិពិធកម្ម។ ការកែលម្អការដឹកជញ្ជូនតាមផ្លូវគោក និងការសម្របសម្រួលនៅថ្នាក់ជាតិ និងមូលដ្ឋាន នឹងជួយបង្កើនតំបន់ទាក់ទាញភ្ញៀវទេសចរកាន់តែច្រើនឡើង។ ការបង្កើនទិន្នផល និងគុណភាពស្រូវ ការកាត់បន្ថយចំណាយលើថ្លៃកិនស្រូវ និងការចំណាយលើផ្នែកភស្តុភារ នឹងជួយលើកកម្ពស់ការប្រកួតប្រជែងនៃស្រូវរបស់កម្ពុជា។

**ការរក្សាស្ថិរភាពក្នុងវិស័យហិរញ្ញវត្ថុដែលកំពុងតែមានការរីកលូតលាស់យ៉ាងលឿន**នឹងទាមទារឲ្យមានការពង្រឹងការគ្រប់គ្រងប្រព័ន្ធធនាគារ ដែលនឹងជួយទប់ស្កាត់ការដួលរលំនៃវិស័យសំណង់។

**ការវិនិយោគបន្ថែមលើវិស័យសុខាភិបាល អប់រំ និងកិច្ចគាំពារសង្គម នឹងជួយបង្កើនផលិតភាព និងសុខុមាលភាព។** កង្វះអាហារូបត្ថម្ភ និងលទ្ធផលសិក្សាទាប នៅតែមានច្រើនក្នុងចំណោមប្រជាជនក្រីក្រ។

**ការពង្រឹងការគ្រប់គ្រងពន្ធ និងការកែលម្អប្រសិទ្ធភាពចំណាយ មានសារៈសំខាន់យ៉ាងខ្លាំង។** ការផ្សារភ្ជាប់ការបង្កើនប្រាក់បៀវត្សរ៍ជាមួយនឹងការគ្រប់គ្រងធនធានមនុស្សកាន់តែប្រសើរ នឹងធ្វើឲ្យការផ្តល់សេវាមានលក្ខណៈកាន់តែប្រសើរ ខណៈដែលការពិនិត្យតាមដានយ៉ាងយកចិត្តទុកដាក់លើការដំឡើងប្រាក់ឈ្នួលនេះនឹងជួយធានាលទ្ធភាពចំណាយលើការដំឡើងប្រាក់ឈ្នួលនេះ។

**ប្រអប់ ៖ និន្នាការនៃភាពក្រីក្រដែលត្រូវវាស់វែងតាមរយៈសមភាពកម្លាំងទិញ (PPP) ដែលរង្វាស់អន្តរជាតិ គឺ ការរកចំណូល បានក្រោម ១,២៥ ដុល្លាអាមេរិកក្នុងមួយថ្ងៃ**

ភាពក្រីក្រនៅកម្ពុជា ដែលប្រើរង្វាស់ ១,២៥ ដុល្លាអាមេរិក (PPP) ក្នុងមួយថ្ងៃ (ដែលផ្តល់លទ្ធភាពឲ្យធ្វើការប្រៀបធៀបជាអន្តរជាតិ) មានចំនួន ៦,0 ភាគរយក្នុងឆ្នាំ២០១២ (រូបលេខ ២) បើធៀបនឹងប្រទេសឡាវ មានចំនួន ២៨,៨ ភាគរយ ប្រទេសហ្វីលីពីន មានចំនួន ១៥,៤ ភាគរយ ហើយប្រទេសឥណ្ឌូនេស៊ី មានចំនួន ១០,៩ ដែលប្រទេសទាំងអស់នេះមានផលិតផលក្នុងស្រុកសម្រាប់មនុស្សម្នាក់លើសពីប្រទេសកម្ពុជាយ៉ាងហោចណាស់ ១,៥ ដង។ ទោះបីជា ភាពក្រីក្រគិតត្រឹមចំណូល ១,២៥ ដុល្លាអាមេរិកក្នុងមួយថ្ងៃ (PPP) បានថយចុះ ដោយមានអត្រាមធ្យមប្រចាំឆ្នាំខ្ពស់ គឺ ៥,៨ ភាគរយ នៅចន្លោះឆ្នាំ ២០០៧ និង ឆ្នាំ២០០៩ អត្រានេះបានថយចុះមកត្រឹមចំនួន ១,៣៦ ភាគរយនៅចន្លោះឆ្នាំ ២០១០ និង ២០១២។ ការថយចុះនៃល្បឿនកាត់បន្ថយភាពក្រីក្រក្នុងប៉ុន្មានឆ្នាំថ្មីៗនេះកើតមានដោយសារតែការធ្លាក់ចុះនៃវិស័យកសិកម្ម ដែលប្រជាជនក្រីក្រពឹងផ្អែកជាចម្បង។

**តារាង៖ ប្រទេសកម្ពុជា** សូចនាករសង្គម និងសេដ្ឋកិច្ច ដែលបានជ្រើសរើស ការព្យាករណ៍ឆ្នាំ២០១៥-២០១៧

| | ឆ្នាំ 2012 | ឆ្នាំ 2013 | ឆ្នាំ2014e | ឆ្នាំ2015p | ឆ្នាំ 2016f | ឆ្នាំ 2017f |
|---|---|---|---|---|---|---|
| GDP ពិត (ការប្រែប្រួលធៀបនឹងឆ្នាំ គិតជា%) | 7.3 | 7.4 | 7.0 | 6.9 | 6.9 | 6.8 |
| GDP នៅតម្លៃទីផ្សារ (ការប្រែប្រួលធៀបនឹងឆ្នាំ គិតជា%) | 8.9 | 8.3 | 7.5 | 7.9 | 8.2 | 8.6 |
| វិស័យកសិកម្ម | 5.6 | 2.0 | 2.2 | 2.3 | 2.8 | 3.3 |
| វិស័យឧស្សាហកម្ម | 13.0 | 13.8 | 13.0 | 11.6 | 10.8 | 9.7 |
| វិស័យសេវាកម្ម | 9.6 | 10.2 | 8.0 | 9.7 | 10.2 | 11.2 |
| អតិផរណា (eop, ការប្រែប្រួលគិតជា %) | 2.5 | 4.6 | 1.2 | 1.5 | 2.0 | 2.5 |
| ជញ្ជីញសារពើពន្ធ រាប់ទាំងជំនួយឥតសំណង (% នៃ GDP) | -3.3 | -2.7 | -2.5 | -3.8 | -4.9 | -4.7 |
| ការនាំចេញ ទំនិញ និងសេវាកម្ម (ការប្រែប្រួលធៀបនឹងឆ្នាំគិតជា %) | 13.7 | 17.6 | 8.9 | 10.6 | 13.0 | 12.7 |
| ការនាំចេញ ទំនិញ និងសេវាកម្ម (ការប្រែប្រួលធៀបនឹងឆ្នាំគិតជា %) | 16.6 | 16.9 | 11.6 | 11.2 | 11.8 | 11.8 |
| សមតុល្យគណនីចរន្តមិនរាប់បញ្ចូលការបង្វែរផ្លូវការ (%GDP) | -9.6 | -10.7 | -11.2 | -11.7 | -11.6 | -10.9 |
| ការវិនិយោគផ្ទាល់ពីបរទេស គិតជាលានដុល្លាអាមេរិក | 1,697.9 | 1,826.1 | 1,717.4 | 1,660 | 1,620 | 1,590 |
| អត្រាភាពក្រីក្រ (បន្ទាត់ភាពក្រីក្រជាតិ) | 17.7 | - | - | - | - | - |
| អត្រាភាពក្រីក្រ (១,២៥ ដុល្លាអាមេរិកក្នុងមួយថ្ងៃ) (PPP) | 6.0 | - | - | - | - | - |
| អត្រាភាពក្រីក្រ (២,០០ ដុល្លាអាមេរិកក្នុងមួយថ្ងៃ)(PPP) | 36.2 | - | - | - | - | - |

ប្រភព ៖ អាជ្ញាធរ និង ការប៉ាន់ស្មាន និងការព្យាករណ៍របស់បុគ្គលិកធនាគារពិភពលោក (និងភាពក្រីក្រ EAP)

e= ការប៉ាន់ស្មានp= ការព្យាករណ៍ (គណនា) f=ការព្យាករណ៍